**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ៣១៦
ចុះថ្ងៃទី ១៤ ខែសីហា ឆ្នាំ ២០០៣
**សាលដីកា**
លេខៈ ៤០
ចុះថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ ២០០៣ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ………… ជាប្រធាន
២-លោក …………. ជាចៅក្រម
៣-លោក …………. ជាចៅក្រម
៤-លោក …………… ជាចៅក្រម
៥-លោក …………… ជាចៅក្រម
៦-លោក …………… ជាចៅក្រម
៧-លោក ………….. ជាចៅក្រម
៨-លោក …………… ជាចៅក្រម
៩-លោក ………….. ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
-អ្នកស្រី ……………….

**តំណាងមហាអយ្យការ**
-ឯកឧត្តម ………… ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ ៩៦(ង) ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ ២០០៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៤៤ ចុះថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះយសស ជាម្ចាស់បណ្តឹងសាទុក្ខ ភេទប្រុស អាយុ៦៣ឆ្នាំជាតិខ្មែរ មុខរបរ ពាណិជ្ជករ ទីលំនៅសព្វថ្ងៃធនាគារសហពាណិជ្ជចំកាត់ ។

មេធាវី លោក ទល ជាតំណាង

និង ចុងចម្លើយឈ្មោះ លហ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ ៥៤ ឆ្នាំជាតិខ្មែរ មុខរបរ ពាណិជ្ជករទីលំនៅផ្ទះលេខ ៦៨ ផ្លូវលេខ១៣៦ សង្កាត់ផ្សារថ្មី១ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មេធាវី លោក កាសរ

***កម្មវត្ថុបណ្តឹងៈ*** ប្តឹងទាមទារប្រាក់ជំពាក់

តាមបណ្តឹងសាទុក្ខលេខ២៦៩ ចុះថ្ងៃទី០៩-៧-០៣ របស់លោក កសវ មេធាវីតំណាងឱ្យលោក លហ ប្តឹងមិនសុខចិត្តនឹងចំណុចទី៤នៃសេចក្តីសម្រេចត្រង់ការប្រាក់២%និងសាលាឧទ្ធរណ៍មិនបានបង្គាប់ ឱ្យធនាគារសហពាណិជ្ជ

ចំកាត់ប្រគល់ប័ណ្ណកម្មសិទ្ធិមកលោក លហ វិញទេ ។

និងបណ្តឹងសាទុក្ខលេខ៣៣២ ថ្ងៃទី០៣-៩-០៣ របស់លោក ទល មេធាវី តំណាងឱ្យធនាគារ សហពាណិជ្ជចំកាត់ ប្តឹងមិនសុខចិត្តនឹងចំណុចទី៤ នៃសេចក្តីសម្រេចក្នុងសាលដីកា និងសុំបន្ថែមការខូចខាតពេលវេលានិងជម្ងឺចិត្ត ចំនួន ៤០.០០០ ដុល្លាអាមេរិក ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៣១៦ ចុះថ្ងៃទី១៤-៨-០៣ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ឈ្មោះ យសសចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០១ បានប្តឹងទាមទារប្រាក់ចំនួន ៥៤៦.៦៧៨ ដុល្លាអាមេរិក ការប្រាក់តាមការព្រមព្រៀង ១.៥% ក្នុង១ខែ និងការប្រាក់បន្ថែមទៀត៣%ក្នុង១ខែ រហូតដល់ថ្ងៃសងគ្រប់ និងជម្ងឺចិត្ត ៣.០០០ ដុល្លាអាមេរិក ពីឈ្មោះ លហ និងប្រពន្ធ មសថ ដោយហេតុថាៈ កាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០០ ឈ្មោះ លហ បានខ្ចីប្រាក់ពីធនាគារសហពាណិជ្ជចំកាត់ ចំនួន៦៤០០០០ដុល្លាអាមេរិក ដោយសន្យាសងតាមកំណត់ដូចខាងក្រោមៈ

-ថ្ងៃទី២២-១២-០០ ដល់ថ្ងៃទី ៣១-០៣-០១ សងចំនួនការប្រាក់រាល់ខែ

-ថ្ងៃទី ៣១-០៣-០១ ដល់ថ្ងៃទី ៣០-០៤-០១ សងចំនួន ៣២០.០០០ដុល្លាអាមេរិក បូកការប្រាក់

-ថ្ងៃទី ៣០-០៤-០១ ដល់ថ្ងៃទី ៣០-០៦-០១ សងការប្រាក់រាល់ខែ

-ថ្ងៃទី ៣០-០៦-០១ ដល់ថ្ងៃទី ៣១-០៧-០១ សង ៣២០.០០០ដុល្លាអាមេរិក បូកការប្រាក់

ក្រោយពីខ្ចីមក លហ មិនគោរពកិច្ចសន្យាខ្ចីចងការប្រាក់នេះទេ ហើយធនាគារបានធ្វើលិខិតរំលឹកច្រើនលើកច្រើនសារ ឲ្យលហ គោរពកិច្ចសន្យា តែពុំព្រមអនុវត្តតាមឡើយ ។

បានឃើញសាលក្រមលេខ ៣៧(ឈ) ចុះថ្ងៃទី២៧ខែសីហា ឆ្នាំ២០០១ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងរបស់ឈ្មោះ យសសប្រធានធនគារសហពាណិជ្ជចំកាត់ ចុះថ្ងៃទី១៣-០៦-០១ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-ទទួស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៣-០៦-០១ របស់ឈ្មោះ យសសប្រគល់ឲ្យមេធាវី ទល ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

៣-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី២៧ ខែ០៦-០១ របស់ឈ្មោះ លហ និងប្រពន្ធឈ្មោះ មសថ ប្រគល់ឲ្យមេធាវី ឡគសនិង ជសហទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

៤-ទទួលស្គាល់ពាក្យសុំខ្ចីចងការប្រាក់ចុះថ្ងៃទី២២-១២-០០ និងកិច្ចសន្យា នៃការចងការប្រាក់ចុះថ្ងៃទី២២-១២-០០ របស់ឈ្មោះ លហ នៅធនាគារសហពាណិជ្ជចំកាត់ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៥-បង្គាប់ឱ្យឈ្មោះ លហ និង ប្រពន្ធឈ្មោះ មសថ ទីលំនៅផ្ទះលេខ ៦៨ អឺ០ ផ្លូវលេខ១៣៦សង្កាត់ផ្សារថ្មី១ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ សងប្រក់ជំពាក់ចំនួន៥៤៦.៦៧៨ដុល្លា( ប្រាំរយសែសិបប្រាំមួយពាន់ ប្រាំមួយរយចិតសិបប្រាំបីដុល្លាអាមេរិក)គិតការប្រាក់ ១,៥% ត្រឹមថ្ងៃទី ៣១-៧-០១ និង ការប្រាក់ ៣% ក្នុង១ខែ គិតពីថ្ងៃទី០១-៨-០១ តទៅដល់ថ្ងៃសងទៅឱ្យប្រធានធនាគារសហពាណិជ្ជកាត់និងជម្ងឺចិត្ត៣០,០០០ដុល្លា (បីម៉ឺនដុល្លាអា

មេរិក) បើឈ្មោះ លហ និង ប្រពន្ធគ្មានប្រាក់សងត្រូវរឹបអូសដី និង ផ្ទះលេខ ច x ០៨២ និងចx ១៣៤ ចុះថ្ងៃទី២១-០២-៩៥,១៨-១១-៩៦ សំណង់កោដនីយដ្ឋាន ហឡូតាមច្បាប់ ។

៦-បង្គាប់ឱ្យឈ្មោះ លហ និង ប្រពន្ធឈ្មោះ មសថ បង់ពន្ធប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន១.៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ ៥០០០៛ បូករួម ៧០០០៛ ដែលដើមចោទបានបង់ទុករួចជាស្រេច ។ កាលបើហួសកំណត់បណ្តឹងឧទ្ធរណ៍ បង្គាប់ឱ្យឈ្មោះ លហ និងប្រពន្ធឈ្មោះ មសថ ប្រគល់ប្រាក់ ៧០០០៛ ទៅឱ្យដើមចោទវិញនិងឱ្យបង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ទាំងអស់ដែលត្រូវសង ប្រាក់នេះដាក់ចូលថវិការដ្ឋ៨០ % និង បានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០%។

៧-សាលក្រមនេះជំនុំជំរះ ជាសាធារណៈចំពោះមុខគូក្តី សម្រេច បើកផ្លូវបណ្តឹងឧទ្ធរណ៍រយៈពេល២ខែ ក្នុងកណត់ច្បាប់ ។

សាលក្រមនេះត្រូវបានឈ្មោះ ឡគស មេធាវីតំណាងឱ្យឈ្មោះ លហប្តឹងឧទ្ធរណ៍តាម បណ្តឹងលេខ ៤៤ ចុះថ្ងៃទី ២៥-១០-០១ មិនសុខចិត្ត នឹងចំណុចទី០៥ ទី០៦ នៃសាលក្រម ។

បានឃើញសាលដីកាលេខ ៣៧"ណា ចុះថ្ងៃទី ១២-៣-០២របស់សាលាឧទ្ធរណ៍ដែលសំរេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៥-១០-០១របស់លោកមេធាវី ឡគស ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹង គតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ៣៧(ល) ផ្ទុះថ្ងៃទី២៧-៨-០១ របស់តុលាការក្រុងភ្នំពេញទុកជា បានការ ដដែល ដោយគ្រាន់តែសម្រេចបដិសេធចោលនូវសំណងជំងឺចិត្តចំនួន ៣០,០០០ដុល្លា (បីម៉ឺនដុល្លាអាមេរិក) ក្នុងចំណុចទី៥ នៃសេចក្តីសម្រេចចោល ។ ចំណុចក្រៅពីនេះរក្សាទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីចំនួន ១៣០០០រៀល ដើមចោទបានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន ២,៥៥០៛ អង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ រង្វាន់អ្នកប្រគល់ដីកាកោះចំនួន ៥.០០០៛ និងចំណាយលើអាផ្កាធរតុលាការចំនួន៥០០០៛ នៅពេលសាលដីកានេះចូលជាស្ថាពរបង្ខំឱ្យចុងចម្លើយសងប្រាក់១៣០០០រៀល នេះទៅដើមចោទវិញ ។

៤-សាលដីការនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីតំណាងឲ្យគូភាគី ។បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១៧២ ចុះថ្ងៃទី១០-៥-០២ របស់លោក កាសវ មេធាវីតំណាងឱ្យចុង ចម្លើយ ឈ្មោះ លហ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៣៧(ឈ)ចុះថ្ងៃទី ១២-០៣-០២ របស់ សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១១១ ចុះថ្ងៃទី១៣-០៥-០៣ របស់តុលាការកំពូលដែលសម្រេចៈ

១-ទទួលបណ្តឹងសាទុក្ខលេខ ១៧២ ចុះថ្ងៃទី ១០-៥-០២ របស់មេធាវី កាសវ ទុកជាត្រឹមត្រូវទាំងទម្រង់ ទាំងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៣៧(ឈ) ចុះថ្ងៃទី ១២-៣-០២ របស់សាលាឧទ្ធរណ៍ ទាំងមូល។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៥៩ ចុះថ្ងៃទី ០៨-០៨-០២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីដែលលោក យសស បានបង់ទុកនៅតុលាការកំពូល ចំនួន១៩០០០រៀល គឺៈ

-ពន្ធចុះបញ្ជីក្តីនិងពន្ធហ៊ឹងចំនួន៤០០០រៀលប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសម្រាប់ជាវង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់.

-ចំណាយលើការប្រគល់ដីកាកោះ ចំនួន ១៥០០០រៀល សរុបចំនួន ១៩០០០រៀល ។

៥-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ ។

សាលាឧទ្ធរណ៍បានសម្រេចសេចក្តីជាថ្មីឡើងវិញតាមអំណាចសាលដីការដ្ឋប្បវេណីលេខ ៩៦(ង) ចុះថ្ងៃទី ០៤-០៧-០៣ មានខ្លឹមសារដូចតទៅៈ

១-ទទួលជំនុំជំរះរឿងរដ្ឋប្បវេណីលេខ ៤៤ ចុះថ្ងៃទី ០៦-៦-០៣ តាមសាលដីការដ្ឋប្បវេណីលេខ ១១១ ចុះថ្ងៃទី ១៣-០៥-០៣ របស់តុលាការកំពូល ។

២-បង្គាប់ឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសងប្រាក់ដើមចំនួន៥៤៦.៦៧៨ដុល្លា(ប្រាំយសែសិបប្រាំមួយពាន់ប្រាំមួយរយចិតសិបប្រាំបីដុល្លាអាមេរិក) និង ការប្រាក់ចំនួន ១២១.៤០៥,៥៩ដុល្លា (មួយរយម្ភៃមួយ ពាន់បួនរយប្រាំដុល្លាអាមេរិក) ទៅឱ្យធនាគារសហពាណិជ្ជចំកាត់នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៣-ក្នុងករណីដែលរដ្ឋ ឬ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គ្មានប្រាក់សង អនុញ្ញាតឱ្យធនាគារសហពាណិជ្ជចំកាត់ទូទាត់ប្រាក់ជំពាក់ ដែលបានសម្រេចក្នុងចំណុចទី២ នៃសាលដីកានេះជាមួយប្រាក់ពន្ធដែលធនាគារសហពាណិជ្ជចំកាត់ត្រូវបង់ពន្ធជូនរដ្ឋ ។

៤-បង្គាប់ឲ្យឈ្មោះ លហ និងឈ្មោះ មសថ បង់ការប្រាក់ ២% ក្នុង១ខែលើប្រាក់ដើមចំនួ ៥៤៦.៦៧៨ដុល្លាអាមេរិក ចាប់គិតពីថ្ងៃទី ១៨-០៧-០២ រហូតដល់ថ្ងៃទីសងគ្រប់ចំនួន ទៅឱ្យធនាគារសហពាណិជ្ជកាត់ ។

**សំណូមពរលើសពីនេះបដិសេធចោល ។**

៥-ក្នុងករណីឈ្មោះ លហ និង ឈ្មោះ មសថ គ្មានប្រាក់សងអនុញ្ញាតឱ្យរឹបអូសទ្រព្យដែលឈ្មោះ លហ និងមសថ ដាក់បញ្ចាំធនាគារសហពាណិជ្ជចំកាត់លក់ឡាយឡុងដើម្បីយកប្រាក់សងបំណុល ។

បើរឹងរូសអនុញ្ញតឱ្យដាក់គុកបង្ខំលើរូបកាយ ។

៦-បង្គាប់ឱ្យឈ្មោះ លហ និងមសថ បង់ពន្ធសមាមាត្រ១% លើទឹកប្រាក់ដែលបានសម្រេចក្នុងចំណុចទី០៤ នៃសាលដីកានេះ ។

៧-សាលដីកានេះជំនុំជំរះនៅថ្ងៃទី០៤-៧-០៣ ពេលព្រឹកចំពោះមុខលោក កាសវ មេធាវីតំណាង ឱ្យលោក លហ តំណាងធនាគារសហពាណិជ្ជចំកាត់ លោកមេធាវី ទល តំណាងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ លោក វង្ស ដាវ និងលោក ឃិន ត័យឈន់ និង ប្រកាសជាសាធារណៈនៅថ្ងៃទី០៤-៧-០៣ វេលា ម៉ោង ៣ និង៣០នាទីល្ងាច ចំពោះមុខលោកមេធាវី កាសវ លោក វង្ស ដាវ តំណាងក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ កំបាំងមុខលោកមេធាវី ទល ។

**បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។**

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ ២៦៩ ចុះថ្ងៃទី ០៩-៧-០៣ របស់លោក គសវ មេធាវី តំណាងឱ្យឈ្មោះ លហ និងបណ្តឹងសាទុក្ខលេខ ៣៣២ ចុះថ្ងៃទី០៣-០៩-០៣ របស់លោកទល មេធាវីតំណាងឲ្យធនាគារសហពាណិជ្ជចំកាត់ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈ សាលដីការដ្ឋប្បវេណីលេខ ៩៦(ង) ចុះថ្ងៃទី ០៤-០៧-០៣ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះពុំមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ឡើយ ។

បានឃើញសារណា សារណាពតប របស់មេធាវី កាសវ ចុះថ្ងៃទី ០៦-១០-០៣

បានឃើញសារណា សារណាតប របស់មេធាវី ទល ចុះថ្ងៃទី ១៨-១១-០៣

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីទល តំណាងឱ្យធនាគារUCB នាពេលសវនាការថាៈ មកដល់ ថ្ងៃសវនាការនេះ ធនាគារUCB មិនទាន់បានទទួលទាំងប្រាក់ដើម និង ការប្រាក់នៅឡើយ ។ រដ្ឋទទួលស្គាល់តែ សំណងនៃការខូចខាតកាលពីថ្ងៃទី ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ប៉ុណ្ណោះ ។

រដ្ឋមិនបានប្តឹងពីសេចក្តីសម្រេច របស់សាលាឧទ្ធរណ៍ទេ ។ នៅតុលាការថ្នាក់ក្រោម លហ សំណូមពរ តែ ២ ចំណុចទេ គឺ

-ស៊ីពន្យាពេល ១ ឆ្នាំ

-សុំកុំឱ្យពិន័យ និង ជម្ងឺចិត្ត

តែមកដល់តុលាការកំពូលស្រាប់តែសុំឱ្យរួចការប្រាក់ទៀត ។

UCB យល់ព្រមថានឹងបញ្ចុះការប្រាក់ពី ៣% ក្នុងសារណាមកត្រឹម ១៥% ។.

សុំតុលាការមេត្តាពិនិត្យ និង ពិចារណាតាមសមធម៌ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងឱ្យលោក លហ នាពេលសវនាការថា ក្រសួងមិនមែន គ្មានលុយទេ តែមកពីនៅជាប់បណ្តឹងសាទុក្ខ ។ សាលាឧទ្ធរណ៍កាត់ឱ្យបែងចែកលុយ ១.៧០០.០០០ដុល្លាអាមេរិក ជាបីចំណែក តែតាមពិតធនាគារកាណាឌីយ៉ា មិនបានប្តឹងទេ ។

សាលាឧទ្ធរណ៍មិនបានកាត់ឱ្យ UCB ប្រគល់ប័ណ្ណកម្មសិទ្ធិមកឱ្យ លហ វិញទេ ។ ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអញ្ជើញ UCB ទៅទូទាត់ជាមួយ តែUCB មិនទៅទូទាត់ទេ ។

UCB សុំតែ១,៥% តែឧទ្ធរណ៍កាត់ឱ្យដល់ទៅ ២% ។

ពីថ្ងៃទី១៣-៣-០២រហូតមកដល់បច្ចុប្បន្នកូនក្តីខ្លួនសុំមិនទទួលសងការប្រាក់ទេ ព្រោះនជាកំហុស UCB។

សុំឱ្យ UCB ប្រគល់ប័ណ្ណកម្មសិទ្ធិមកឱ្យកូនក្តីខ្លួនវិញ ។

សុំតុលាការមេត្តាពិចារណាកុំឱ្យគិតការប្រាក់ពីថ្ងៃទី ១៣-០៣-០២ រហូតមកដល់បច្ចុប្បន្ននិងសុំកុំឱ្យ មានពិន័យ និង ជម្ងឺចិត្ត ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋារបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៦៩ ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០០៣ របស់លោក កាសវមេធាវីតំណាងឲ្យឈ្មោះ លហ និងបណ្តឹងសាទុក្ខលេខ ៣៣២ ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០៣ របស់លោក ទលមេធាវីតំណាងឱ្យធនាគារសហពាណិជ្ជចំកាត់ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី និង មាត្រ ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលមានអានុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

-យល់ឃើញថា ចុងចម្លើយបានទទួលស្គាល់ប្រាក់ជំពាក់ធនាគារសហពាណិជ្ជចំកាត់ចំនួន ៥៤៦.៦៧៨ ដុល្លាអាមេរិក ហើយការប្រាក់ដែលចុងចម្លើយមិនបានបង់ គឺពីថ្ងៃទី ១៥-០៨-២០០១ រីឯភាគីដើមចោទក៏បានឯកភាពទទួលស្គាល់ចំពោះការលើកឡើងនេះដែរ ។

-យល់ឃើញថា បំណុលដែល លហ ជំពាក់ធនាគារសហពាណិជ្ជចំកាត់ខាងលើនេះ ត្រូវបានផ្ទេរទៅជាបំណុលរបស់រដ្ឋជាមួយធនាគារសហពាណិជ្ជចំកាត់វិញ តាមលិខិតលេខ ៨៥៣ សហវ ចុះថ្ងៃទី១១ ខែមីនា ថឆ្នាំ២០០១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

-យល់ឃើញថា បំណុលរបស់ធនាគារទាំងប្រាក់ដើមទាំងការប្រាក់សរុបចំនួន ៥៤៦.៦៧៨ដុល្លាអាមេរិក និង ១២១៤០៥៨៩ដុល្លាអាមេរិក ត្រូវបានដើមចោទយល់ព្រមទទួលយកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុហើយៗចំណុចនេះក្នុងសាលដីកាសាលាឧទ្ធរណ៍ក៏បានចូលជាស្ថាពររួចហើយ ដូច្នេះលោក លហ ត្រូវបានរួចផុតពីកាតព្វកិច្ចចំពោះធនាគារសហពាណិជ្ជដែរ ហើយធនាគារសហពាណិជ្ជត្រូវបង្វិលប័ណ្ណសំគាល់អចលនៈទ្រព្យដែលដាក់ធានាបំណុលឱ្យមក លោក លហ វិញ ។

-យល់ឃើញថាភាគីចុងចម្លើយនិងដើមចោទបានប្តឹងសាទុក្ខតែលើចំណុចទី ៤នៃសាលដីការដ្ឋប្បវេណីលេខ ៩៦(ង) ចុះថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ តែប៉ុណ្ណេះ ។

-យល់ឃើញថា តាមរយៈលិខិតលេខ ៨៥៣ សហវ ចុះថ្ងៃទី ១១ ខែ មិនា ឆ្នាំ២០០២ របស់ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានអញ្ជើញភាគីធនាគារមកដោះស្រាយទូទាត់បំណុលនេះ ឯធនាគារក៏បានទទួលលិខិត អញ្ជើញនេះតាំងពីខែ មិនា ឆ្នាំ២០០២ ហើយដែរ ប៉ុន្តែភាគីដើមចោទ ធនាគារមិនបានធ្វើអំពើចាំបាច់ដើម្បី ទទួលការទូទាត់នេះទេ ។ តាមគោលការណ៏ច្បាប់រដ្ឋប្បវេណីកូនបំណុលមិនទទួលខុសត្រូវចំពោះការមិនអនុវត្ត កាតព្វកិច្ចរបស់ម្ចាស់បំណុល ឡើយ ។ ដូច្នេះការប្រាក់ដែលតម្រូវឱ្យក្រុមហ៊ុន លហ បង់សងទៅធនាគារ ត្រង់ចំណុចទី ៤នៃសាលដីការដ្ឋប្បវេណីលេខ ៩៦ (ង) ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ ពុំមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ឡើយ ។

-យល់ឃើញថា លោកមេធាវី ចុងចម្លើយជានថ្លែងសាទុក្ខតែលើចំណុចទី ៤នៃសាលដីការបស់សាលា ឧទ្ធរណ៏មែន ប៉ុន្តែចំណុចទី ៤ នេះមានការទាក់ទងគ្នាជាមួយចំណុចទី៥ និងទី៦ ។ ដូច្នេះតាមមាត្រាទី២២១ វាក្យខ័ណ្ឌទី៣នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលមានអានុភាពអនុវត្តក្នុងរឿងរដ្ឋប្បវេណីផងដែរ តុលាការអាចលើកយកចំណុចទិ៥និង

ទី៦ មកពិនិត្យ និងសម្រេចបានដែរ ។

-យល់ឃើញថា ការដែលមេធាវីដើមចោទប្តឹងសាទុក្ខទាមទារការខូចខាត និង ជម្ងឺចិត្តចំនួន៤០.០០០ ដុល្លាអាមេរិក នោះតុលាការកំពូល ពុំអាចពិចារណាបានទេ ពីព្រោះនៅពេលជំនុំជំរះលើកទី ១ សាលាឧទ្ធរណ៍ បានទុកជាមោឃៈផ្លូវជម្ងឺចិត្តនេះហើយប៉ុន្តែលោកពុំបានប្តឹងសាទុក្ខទេ ។ ទើបនឹងប្តឹងសាទុក្ខលើកទី២ ប៉ុណ្ណោះ ។

-យល់ឃើញថា ការដែលមេធាវីចុងចម្លើយលើកឡើងនាពេលសវនាការនេះថា សុំឱ្យកាត់ការប្រាក់ពីថ្ងៃទី ១៣-០៣-០២ ដល់ថ្ងៃទី១៨-០៧-០២ ចេញនោះ តុលាការកំពូលពុំអាចពិចារណាបានទេ ពីព្រោះលោកពុំបាន ប្តឹងសាទុក្ខពីចំណុចនេះទេ ។

-យល់ឃើញថា គូភាគីពុំបានមកចូលរួមនាសវនាការនេះទេ មានតែមេធាវីមកចូលរួម ដូច្នេះ តុលាការ កំពូលជំនុំជំរះកំបាំងមុខ ចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៩៦(ង) ចុះថ្ងៃទី ០៤-៧-០៣ របស់សាលាឧទ្ធរណ៍ត្រង់ ចំណុចទី ៤ មានការខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខគូភាគី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលពាក្យបណ្តឹងសាទុក្ខលេខ ២៦៩ ចុះថ្ងៃទី ០៩-៧-០៣ របស់លោកមេធាវី កាសវ តំណាងឱ្យឈ្មោះ លហ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងសាទុក្ខលេខ ៣៣២ ចុះថ្ងៃទី ០៣-៩-០៣ របស់លោកមេធាវី ទល តំណាងឱ្យធនាគារសហពាណិជ្ជចំកាត់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

៣-ទុកជាមោឃៈចំណុចទី៤ ទី៥ និង ទី៦ នៃសាលដីការដ្ឋប្បវេណីលេខ ៩៦ (ង)ចុះថ្ងៃទី ០៤ ខែកក្កដាឆ្នាំ ២០០៣ របស់សាលាឧទ្ធរណ៍ ហើយតម្រូវឱ្យធនាគារសហពាណិជ្ជចំកាត់បង្វិលប័ណ្ណកម្មសិទ្ធិនៃវត្ថុដែលបានដាក់ប្រាតិភោគមកឱ្យក្រុមហ៊ុន លហ វិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០៛ ដែលដើមចោទបានបង់គឺៈ

-ពន្ធចុះបញ្ជីក្តីនិងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើការប្រគល់ដីកាកោះ ចំនួន ១៥០០០រៀល សរុបចំនួន ១៩០០០រៀល ។

៥-សាលដីកានេះជំនុំជំរះ នៅថ្ងៃទី ១២ខែ កុម្ភៈ ឆ្នាំ ២០០៤ និង ប្រកាសជាសាធារណៈនៅថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០០៤ ។